ក្រសួងយុត្តិធម៌ នៃព្រះរាជាណាចក្រកម្ពុជា
Ministry of Justice, Kingdom Of Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ការអនុវត្តសេចក្តីសម្រេចចិត្តដាក់ទណ្ឌកម្ម របស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ អនុលោមតាមច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទាន ដល់ការរីកសាយភាយអាវុធមហាប្រល័យ





**ប៉ែន ពេជ្រសាលី**
អគ្គនាយកកិច្ចការអយ្យការ និងព្រហ្មទណ្ឌ
ក្រសួងយុត្តិធម៌

# មាតិកា


១.នីតិវិធីនៃការស្នើសុំបង្កកទ្រព្យសម្បត្តិ

២.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិរបស់សាលាដំបូងរាជធានីភ្នំពេញ

៣.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១១ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ ( កូរ៉េខាងជើង )

៤.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១២ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ ( អ៊ីរ៉ង់ )

៥.ទម្រង់របាយការណ៍របស់បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍

៦.ការផ្សព្វផ្សាយជាសាធារណៈនៅក្នុងគេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌

៧.ទោសប្បញ្ញត្តិពាក់ព័ន្ធនឹងរូបវន្តបុគ្គល

៨.ទោសប្បញ្ញត្តិពាក់ព័ន្ធនឹងនីតិបុគ្គល

# ១.នីតិវិធីនៃការស្នើសុំបង្កកទ្រព្យសម្បត្តិ (ខ្លឹមសារមាត្រា ៤)

ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិបញ្ជូនសេចក្តីសម្រេចចិត្តដាក់ឈ្មោះបុគ្គលឬអង្គភាពក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះមកក្រសួងយុត្តិធម៌។

ក្រសួងយុត្តិធម៌បញ្ជូនសេចក្តីសម្រេចចិត្តនោះទៅសាលាដំបូងរាជធានីភ្នំពេញ ដើម្បីស្នើសុំបង្កកទ្រព្យសម្បត្តិដូចខាងក្រោម៖

ក. ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិ ឬគ្រប់គ្រងដោយបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី ទោះមួយផ្នែកឬទាំងស្រុង ដោយផ្ទាល់ឬដោយប្រយោលក្តី ហើយមិនមែនត្រឹមតែជាទ្រព្យសម្បត្តិដែលអាចជាប់ជាមួយសកម្មភាព ផែនការទុច្ចរិត ឬការគំរាមកំហែងជាក់លាក់នោះទេ។

ខ.ទ្រព្យសម្បត្តិរបស់បុគ្គលឬអង្គភាពតំណាង ឬស្ថិតក្រោមការដឹកនាំផ្ទាល់ពីបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជី។

គ.ទ្រព្យសម្បត្តិបង្វែរមកពី ឬកេីតបានមកពីទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងចំណុច (ក) និង (ខ)។

ឃ.នាវាជាប់ឈ្មោះក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ អនុលោមតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ។

សេចក្តីសម្រេចបង្កកទ្រព្យសម្បត្តិចេញដោយតុលាការពុំមានរយៈពេលកំណត់ឡើយ លើកលែងតែសេចក្តីសម្រេចនោះត្រូវបានលុបចោល។

UN Security Council

ព្រះរាជាណាចក្រកម្ពុជា
ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

ក្រសួងយុត្តិធម៌
Ministry of Justice

សាលាដំបូងរាជធានីភ្នំពេញ

# ២.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិរបស់សាលាដំបូងរាជធានីភ្នំពេញ

សាលាដំបូងរាជធានីភ្នំពេញ

ក្រោយពីបានទទួលសេចក្ដីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ តាមរយៈក្រសួងយុត្តិធម៌ដើម្បីចេញសេចក្ដីសម្រេចបង្កកទ្រព្យសម្បត្តិ សាលាដំបូងរាជធានីភ្នំពេញបានចេញនូវដីកាសម្រេចបង្កកទ្រព្យសម្បត្តិចំនួន០២ ៖

១.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១១ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មលើសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ





២.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១២ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ ពាក់ព័ន្ធនឹងការដាក់ទណ្ឌកម្មលើប្រទេសអ៊ីរ៉ង់។





# ៣.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១១ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ

១-យោងតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ៖

UN Security Council

SANCTION



១.លេខ១៧១៨ (២០០៦) អនុម័តនៅថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៦

២.លេខ១៨៧៤ (២០០៩) អនុម័តនៅថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ២០០៩

៣.លេខ២០៨៧ (២០១៣) អនុម័តនៅថ្ងៃទី ២២ ខែ មករា ឆ្នាំ២០១៣

៤.លេខ២០៩៤ (២០១៣) អនុម័តនៅថ្ងៃទី០៧ខែមីនា ឆ្នាំ ២០១៣

៥.លេខ២២៧០ (២០១៦) អនុម័តនៅថ្ងៃទី ០២ ខែ មីនា ឆ្នាំ២០១៦

៦.លេខ២៣២១ (២០១៦) អនុម័តនៅថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០១៦

៧.លេខ២៣៧១ (២០១៧) អនុម័តនៅថ្ងៃទី០៥ ខែ សីហាឆ្នាំ ២០១៧

៨.លេខ២៣៧៥ (២០១៧) អនុម័តនៅថ្ងៃទី១១ ខែ កញ្ញា ឆ្នាំ ២០១៧

៩.លេខ២៣៩៧ (២០១៧) អនុម័តនៅថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ២០១៧

និងសេចក្តីសម្រេចចិត្តជាបន្តបន្ទាប់ពាក់ព័ន្ធនឹងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ

សាលាដំបូងរាជធានីភ្នំពេញបានសម្រេចបង្កកទ្រព្យសម្បត្តិរបស់បុគ្គល ឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីនៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សានេះ និងហាមឃាត់មិនឱ្យមានការលក់ ផ្ទេរ បំប្លែង ផ្គត់ផ្គង់ ធ្វើភតិសន្យា ធ្វើមត៌ក ធ្វើអនុប្បទាន ចល័ត ឬប្រើប្រាស់ ចំពោះទ្រព្យសម្បត្តិទាំងអស់ ដូចខាងក្រោម៖

១.១-ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិឬគ្រប់គ្រងដោយបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីខាងលើ ទោះមួយផ្នែក ឬទាំងស្រុង ដោយផ្ទាល់ ឬដោយប្រយោលក្តីហើយមិនមែនត្រឹមតែជាទ្រព្យសម្បត្តិដែលអាចជាប់ជាមួយសកម្មភាព ផែនការទុច្ចរិត ឬការគំរាមកំហែងជាក់លាក់នោះទេ។

១.២-ទ្រព្យសម្បត្តិរបស់បុគ្គល ឬអង្គភាពតំណាង ឬស្ថិតក្រោមការដឹកនាំផ្ទាល់ពីបុគ្គល ឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីខាងលើ។

១.៣-ទ្រព្យសម្បត្តិបង្វែរមកពី ឬបានមកពីទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងវាក្យខណ្ឌ១.១ដល់១.២នៃសេចក្តីសម្រេចនេះ។

១.៤-នាវាជាប់ឈ្មោះក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ អនុលោមតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិខាងលើ។

## ៣.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១១ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ (ត)

២-បង្គាប់មកបុគ្គលរាយការណ៍ឱ្យផ្ញើរបាយការណ៍ក្នុងរយៈពេលមិនលើសពី ៣ (បី) ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិនិងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកជូនអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្រោយពីបានបង្កកទ្រព្យសម្បត្តិរួច។

៣-បង្គាប់មកបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ឱ្យផ្ញើរបាយការណ៍ក្នុងរយៈពេលមិនលើសពី ៣ (បី) ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិនិងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកជូនទៅក្រសួងយុត្តិធម៌ ក្រោយពីបានបង្កកទ្រព្យសម្បត្តិរួច។

៤-បង្គាប់មករាល់បុគ្គល ឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិដែលត្រូវបានបង្កកតាមដីកាសម្រេចនេះឱ្យបង្កកទ្រព្យសម្បត្តិទាំងនោះដោយគ្មានបង្អង់ និងដោយគ្មានការជូនដំណឹងជាមុន។

៥-ក្រសួង ស្ថាប័នត្រួតពិនិត្យត្រូវតាមដានបុគ្គលរាយការណ៍ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ដើម្បីធានាការអនុវត្តដីកាសម្រេចនេះយោងតាមបញ្ញត្តិនៃមាត្រា១៦នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

# ៤.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១២ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ

១-យោងតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ៖

UN Security Council

SANCTION



១.លេខ១៧៣៧ (២០០៦)អនុម័ត ថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០០៦

២.លេខ ២២៣១ (២០១៥) អនុម័ត ថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០១៥

សេចក្តីសម្រេចចិត្តជាបន្តបន្ទាប់ពាក់ព័ន្ធនឹងប្រទេសអ៊ីរ៉ង់

សាលាដំបូងរាជធានីភ្នំពេញបានសម្រេចបង្កកទ្រព្យសម្បត្តិរបស់បុគ្គល ឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីនៃសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សានេះ និងហាមឃាត់មិនឱ្យមានការលក់ ផ្ទេរ បំប្លែង ផ្លត់ផ្លង់ ធ្វើកតិសន្យា ធ្វើមត៌ក ធ្វើអនុប្បទាន ចល័ត ឬប្រើប្រាស់ ចំពោះទ្រព្យសម្បត្តិទាំងអស់ដូចខាងក្រោម៖

១.១-ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិឬគ្រប់គ្រងដោយបុគ្គលឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីខាងលើ ទោះមួយផ្នែក ឬទាំងស្រុង ដោយផ្ទាល់ ឬដោយប្រយោលក្តីហើយមិនមែនត្រឹមតែជាទ្រព្យសម្បត្តិដែលអាចជាប់ជាមួយសកម្មភាព ផែនការទុច្ចរិត ឬការគំរាមកំហែងជាក់លាក់នោះទេ។

១.២-ទ្រព្យសម្បត្តិរបស់បុគ្គល ឬអង្គភាពតំណាង ឬស្ថិតក្រោមការដឹកនាំផ្ទាល់ពីបុគ្គល ឬអង្គភាពជាប់ឈ្មោះក្នុងបញ្ជីខាងលើ។

១.៣-ទ្រព្យសម្បត្តិបង្វែរមកពី ឬបានមកពីទ្រព្យសម្បត្តិដែលបានកំណត់នៅក្នុងវាក្យខណ្ឌ១.១ ដល់១.២នៃសេចក្តីសម្រេចនេះ។

១.៤-នាវាជាប់ឈ្មោះក្នុងបញ្ជីដោយក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិ ឬគណៈកម្មាធិការនៃក្រុមប្រឹក្សានេះ អនុលោមតាមសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខនៃអង្គការសហប្រជាជាតិខាងលើ។

## ៤.ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១២ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ (ត)

២-បង្គាប់មកបុគ្គលរាយការណ៍ឱ្យផ្ញើរបាយការណ៍ក្នុងរយៈពេលមិនលើសពី ៣ (បី) ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិនិងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកជូនអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជាក្រោយពីបានបង្កកទ្រព្យសម្បត្តិរួច។

៣-បង្គាប់មកបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ឱ្យផ្ញើរបាយការណ៍ក្នុងរយៈពេលមិនលើសពី៣ (បី) ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិនិងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកជូនទៅក្រសួងយុត្តិធម៌ ក្រោយពីបានបង្កកទ្រព្យសម្បត្តិរួច។

៤-បង្គាប់មករាល់បុគ្គល ឬអង្គភាពដែលកំពុងកាន់កាប់ទ្រព្យសម្បត្តិដែលត្រូវបានបង្កកតាមដីកាសម្រេចនេះឱ្យបង្កកទ្រព្យសម្បត្តិទាំងនោះដោយគ្មានបង្អង់ និងដោយគ្មានការជូនដំណឹងជាមុន។

៥-ក្រសួង ស្ថាប័នត្រួតពិនិត្យត្រូវតាមដានបុគ្គលរាយការណ៍ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ខ្លួន ដើម្បីធានាការអនុវត្តដីកាសម្រេចនេះយោងតាមបញ្ញត្តិនៃមាត្រា១៦នៃច្បាប់ស្តីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ។

# ៥.ទម្រង់របាយការណ៍របស់បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍

បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ដែលបានបង្កកទ្រព្យសម្បត្តិស្របតាមមាត្រា៦នៃច្បាប់នេះ ត្រូវរាយការណ៍ក្នុងរយៈពេលមិនលើសពី៣(បី)ថ្ងៃ អំពីការបង្កកទ្រព្យសម្បត្តិ និងរាល់ការប៉ុនប៉ងធ្វើប្រតិបត្តិការទៅលើទ្រព្យសម្បត្តិដែលបានបង្កកទៅក្រសួងយុត្តិធម៌ (មាត្រា១៣)។ បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ត្រូវរាយការណ៍តាមទម្រង់ដែលបានកំណត់នៅក្នុងប្រកាសលេខ ១៨៤ កយ ប្រក/២០ ស្ដីពីទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដែលត្រូវធ្វើដោយបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ ដែលមានផ្សព្វផ្សាយនៅក្នុងគេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌។









<u>កំណត់សម្គាល់</u>៖ ចំពោះបុគ្គលរាយការណ៍ដែលជាប់កាតព្វកិច្ចតាមមាត្រា១២ (កាតព្វកិច្ចរាយការណ៍របស់បុគ្គលរាយការណ៍) នៃច្បាប់ស្ដីពីការប្រឆាំងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យត្រូវរាយការណ៍ទៅអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា ដែលនឹងត្រូវចាត់វិធានការដោយឡែកតាមមាត្រា១២ (កាតព្វកិច្ចរាយការណ៍របស់បុគ្គលរាយការណ៍) នៃច្បាប់ដដែលនេះ។

# ៦.ការផ្សព្វផ្សាយជាសាធារណៈនៅក្នុងគេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌



នៅថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២០ ក្រសួងយុត្តិធម៌បានចេញសេចក្តីជូនដំណឹងជាសាធារណៈ និងបានផ្សព្វផ្សាយនៅក្នុងគេហទំព័រផ្លូវការរបស់ក្រសួងយុត្តិធម៌នូវឯកសារដូចខាងក្រោម៖

- ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ១១ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ( http://moj.gov.kh/kh/announcement/150 )
- ដីកាសម្រេចបង្កកទ្រព្យសម្បត្តិលេខ ១២ ចុះថ្ងៃទី០២ ខែ វិច្ឆិកា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ ( http://moj.gov.kh/kh/announcement/149 )
- ប្រកាសលេខ ១៨៤ កយ ប្រក/២០ ស្តីពីទម្រង់នៃរបាយការណ៍អំពីការបង្កកទ្រព្យសម្បត្តិដែលត្រូវធ្វើដោយបុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ ( http://moj.gov.kh/kh/announcement/160 )
- សេចក្តីជូនដំណឹងជាសាធារណៈដល់បុគ្គល ឬអង្គភាពក្រៅពីបុគ្គលរាយការណ៍ ( http://moj.gov.kh/kh/announcement/155 )

# ៧.ទោសប្បញ្ញត្តិពាក់ព័ន្ធនឹងរូបវ័ន្តបុគ្គល

**បទល្មើសនៃការបំពានសេចក្តីសម្រេចបង្កក (មាត្រា១៩)**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត ជនណាដែលមិនអនុវត្តតាមសេចក្តីសម្រេចរបស់តុលាការដូចមានចែងក្នុងមាត្រា៦(ការបង្កកទ្រព្យសម្បត្តិ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី២(ពីរ)ឆ្នាំទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ចំនួន ២០ ០០០ ០០០ (ម្ភៃលាន)រៀល ទៅ៥០ ០០០ ០០០ (ហាសិបលាន)រៀល។

**បទល្មើសនៃការប្រគល់ទ្រព្យសម្បត្តិ (មាត្រា២០)**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត ជនណាប្រគល់ទ្រព្យសម្បត្តិទាំងអស់ឬមួយផ្នែកទោះដោយផ្ទាល់ ឬប្រយោលក្តី ឬប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះជាផលប្រយោជន៍ដល់បុគ្គល ឬអង្គភាពដូចមានចែងក្នុងមាត្រា១០(ការហាមឃាត់មិនឱ្យប្រើប្រាស់ទ្រព្យសម្បត្តិ)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី៧(ប្រាំពីរ)ឆ្នាំ ទៅ១៥(ដប់ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី៥០ ០០០ ០០០ (ហាសិបលាន)រៀលទៅ២០០ ០០០ ០០០(ពីររយលាន)រៀល។

**បទល្មើសនៃការបំពានកាតព្វកិច្ចរាយការណ៍ (មាត្រា២១)**

ដោយមិនទាន់គិតដល់បទល្មើសព្រហ្មទណ្ឌដទៃទៀត ជនណាមិនបានរាយការណ៍ស្របតាមមាត្រា១២(កាតព្វកិច្ចរាយការណ៍របស់បុគ្គលរាយការណ៍)និងមាត្រា១៣(កាតព្វកិច្ចរាយការណ៍របស់បុគ្គលឬអង្គភាពក្រៅពីបុគ្គលរាយការណ៍)នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី១(មួយ)ខែ ទៅ៦(ប្រាំមួយ)ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន)រៀល ដល់ ១ ០០០ ០០០ (មួយលាន)រៀល។

# ៨.ការទទួលខុសត្រូវរបស់នីតិបុគ្គល (មាត្រា២២)

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា១៩(បទល្មើសនៃការបំពានសេចក្តីសម្រេចបង្កក)នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៣០ ០០០ ០០០ (សាមសិបលាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២០(បទល្មើសនៃការប្រគល់ទ្រព្យសម្បត្តិ)នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី១០០ ០០០ ០០០(មួយរយលាន)រៀល ទៅ៤០០ ០០០ ០០០(បួនរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើនដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

នីតិបុគ្គលអាចត្រូវបានប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដូចមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា២១(បទល្មើសនៃការបំពានកាតព្វកិច្ចរាយការណ៍)នៃច្បាប់នេះ។ នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី៣០ ០០០ ០០០ (សាមសិបលាន)រៀល ទៅ១០០ ០០០ ០០០ (មួយរយលាន)រៀល ព្រមទាំងទោសបន្ថែមមួយឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ។

# សូមអរគុណ!!!